**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០១៧

**សេចក្ដីផ្ដើម** :

នៅក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្ដីស្នើច្បាប់ចំនួន០១ច្បាប់ និងសេចក្ដីព្រាងច្បាប់ចំនួន០២ច្បាប់<br>- បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងក្រុមព្រឹទ្ធសភាហត្ថលេខី និងតំណាងក្រុមតំណាងរាស្ត្រហត្ថលេខី ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីស្នើច្បាប់ចំនួន០១ច្បាប់ និងសេចក្ដីព្រាងច្បាប់ចំនួន០២ច្បាប់ ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្ដារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា<br>- ប្រជុំបន្តពិនិត្យ និងសម្រេចលើសេចក្ដីព្រាងសេចក្ដីសម្រេចរួមស្ដីពី គោលការណ៍ និងលក្ខខណ្ឌនៃការធ្វើសមាហរណកម្ម ក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- ប្រជុំស្ដីពី ការបង្កើតក្រុមការងារបច្ចេកទេសសិក្សាស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងសេចក្ដីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៤ និងក្រុមសីលធម៌សម្រាប់សមាជិកព្រឹទ្ធសភា<br>- ផ្ដល់សេវាភេសជ្ជៈ និងអាហារសម្រន់ចំនួន០៧លើក |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443  ទូរសារ: (855 23) 211 446  E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | មានអ្នកចូលរួមចំនួន២៣២នាក់<br>- ថតចម្លងឯកសារបានចំនួន១,៦៦៣ច្បាប់ និង រៀបចំចងក្រងធ្វើជាសៀវភៅចំនួន១៨ក្បាល អស់ក្រដាសចំនួន១៥,០០៤ សន្លឹក<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និង មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុប ចំនួន២២លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ ផ្សេងៗចំនួន៦៧នាក់ និងកម្លាំងអន្តរាគមន៍ពី ខាងក្រៅស្ថាប័នចំនួន១៣០នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ និង សេចក្តីស្នើច្បាប់ចំនួន០១ច្បាប់ ពីរដ្ឋសភា និង រាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន៤៣ច្បាប់<br>- ធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យ យោបល់តាមឆ្នាំ និងនីតិកាល<br>- បានរៀបចំបោះពុម្ពសៀវភៅស្តីពី សភាប្រទេស កាណាដា<br>- បានរៀបចំឯកសារជំនួយស្មារតីចំនួន០៤ច្បាប់ និងកំពុងបន្តសិក្សាស្រាវជ្រាវលើប្រធានបទសំខាន់ៗ ពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន ០២ច្បាប់ |

| | |
|---|---|
| | - បានសិក្សាស្រាវជ្រាវឯកសារស្តីពី កិច្ចការសភានៃសាធារណរដ្ឋប្រជាមានិតចិន សភាជាតិជប៉ុន និងសភានៃសាធារណរដ្ឋកូរ៉េខាងត្បូង និងឯកសារស្តីពី ដំណើរការនីតិកម្មបណ្តាសភា Westminster ចក្រភពអង់គ្លេស អូស្ត្រាលី និងកាណាដា<br>- បានសិក្សាស្រាវជ្រាវ និងសង្ខេបព័ត៌មានប្រចាំថ្ងៃអំពីសភាប្រទេសនានា<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៧លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន២០លើក<br>- ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹងសេចក្តីប្រកាសព័ត៌មានចំនួន១៩លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មានការអភិវឌ្ឍលើវិស័យនានា នៅខេត្តកោះកុងព្រះសីហនុ កំពត និងខេត្តតាកែវ ។ | - ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥នាក់ ស្មើនឹង០៣ច្បាប់<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគចំនួន១០នាក់ ស្មើនឹង០១លើក ។ |

**៣.មុខងារតំណាង :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ |

| | |
|---|---|
| ព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីរុក្ខទិវា ៩កក្កដា ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកណ្តាល<br>+ អញ្ជើញជូនព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **ព្រះវររាជមាតាជាតិខ្មែរ** យាងទៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ជូនគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង និងខេត្តព្រះសីហនុ<br>+ អញ្ជើញជាអធិបតី និងចូលរួមក្នុងពិធីសម្ពោធស្តូបមិត្តភាពកម្ពុជា វៀតណាម នៅខេត្តព្រះសីហនុ<br>+ អញ្ជើញចូលរួមរំលែកទុក្ខគ្រួសារសពលោកជំទាវ **អេង គីមនាង** អភិបាលរង | សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីក្នុងពិធីផ្សេងៗសរុបចំនួន២៣៤លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា ពិធីបើក និងបិទវគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗចំនួន១៤លើក<br>- បានចងក្រងចំងាយផ្លូវពីទីរួមខេត្តទៅស្រុកនីមួយៗ នៅក្នុងខេត្តតាកែវ កំពត និងខេត្តកែប<br>- បានរៀបចំចងក្រងឯកសារស្តីពីលទ្ធផលនៃការបោះឆ្នោត និងសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ (២០១៤-២០១៨) ដើម្បីបោះពុម្ពជាសៀវភៅ<br>- បានសហការរៀបចំ និងចាត់ចែងពិធីគោរពវិញ្ញាណក្ខន្ធសពចំនួន០៣លើក<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤៧នាក់ ស្មើនឹង៤៣ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១៧នាក់ ស្មើនឹង១៧ច្បាប់<br>- ថតចម្លងឯកសារចំនួន៣៤៩ច្បាប់ អស់ក្រដាស |

| | |
|---|---|
| នៃគណៈអភិបាលខេត្តកោះកុង និង គ្រួសារសពឧបាសក ឡាយ ស្រី ដែលជា ប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ<br>+ អញ្ជើញចុះជួបជាមួយក្រុមគ្រូពេទ្យ និងសាកសួរសុខទុក្ខប្រជាពលរដ្ឋ ដែលមានជំងឺ មកពិនិត្យ និងសម្រាកព្យាបាល នៅមជ្ឈមណ្ឌលពិនិត្យ និងព្យាបាលជំងឺទឹកនោមផ្អែមមិត្តភាពកម្ពុជា កូរ៉េ នៃមន្ទីរពេទ្យព្រះកុសុមៈ រាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមក្នុងពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុក ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន<br>+ អញ្ជើញចូលរួមប្រជុំ និងពិធីជប់លៀង ជូនគណៈប្រតិភូវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញចូលរួមប្រជុំគណៈកម្មការចំពោះកិច្ច ដើម្បីត្រៀមរៀបចំសន្និសីទលើកទី១១ ស្តីពី មិត្តភាពប្រជាជន និងប្រជាជនអាស៊ាន ចិន<br>+ អញ្ជើញនាំយកទេយ្យទាន ទៀនវស្សា និងបច្ច័យប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ចំនួន០៣វត្ត នៅខេត្តតាកែវ | ចំនួន១,២២៤សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគចំនួន១៦៣នាក់ ស្មើនឹង៤០លើក<br>- ទទួលលិខិតចូលចំនួន៧៦៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១៣ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៧២លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗចំនួន១៥នាក់ ស្មើនឹង០២លើក<br>- ផ្តល់អត្ថបទ និងរូបថតចំនួន៤៧១សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន២០៦នាក់ ធ្វើប័ណ្ណសមាជិកចំនួន១១នាក់ ខ្ចីសៀវភៅចំនួន៣៥ក្បាល និងសងវិញចំនួន៥៨ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០៤លើក របស់សាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យអាស៊ីអឺរ៉ុប សាកលវិទ្យាល័យកូឡាំប៊ី សាកលវិទ្យាល័យបាត់ដំបង និងមន្ត្រីការិយាល័យអប់រំយុវជន និងកីឡា មកពីខេត្តព្រៃវែង សរុបចំនួន២៣៥នាក់<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ក្រសួង |

| | |
|---|---|
| - សមាជិកព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យការដ្ឋានជីកស្រះទឹកត្រពាំងធំ ដើម្បីត្រៀមលក្ខណៈរៀបចំពិធីសម្ពោធនាពេលខាងមុខ នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>- បានទទួលពាក្យបណ្តឹងចំនួន០៤ករណី និងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៩ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន១៧១លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព ក្រុមប្រឹក្សាឃុំសង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤៩លើក ។ | ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រឹត្តិបត្រទស្សនាវដ្តីចំនួន១២៨ក្បាល កាសែត និងរាជក្រមចំនួន១៨៩ច្បាប់<br>- ផលិត និងផ្សព្វផ្សាយវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០១លើក<br>- រៀបចំទស្សនាវដ្តីប្រចាំខែកក្កដា ឆ្នាំ២០១៧<br>- ផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូសម្រាប់បង្ហោះលើ Alert News ចំនួន១៦៨ប្រធានបទ<br>- ថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន៤០លើក<br>- ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៩លើក ។ |

### ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានជួបសវនាការជាមួយអគ្គលេខាធិការនៃគណៈកម្មាធិការ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជន |

| | |
|---|---|
| មជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម និងបានអនុញ្ញាតឲ្យប្រធានក្រុមហ៊ុន SHOUNGANG FUND និងគណៈប្រតិភូក្រុមយុវជនរបស់សមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា មកពីប្រទេសបារាំង ចូលជួបពិភាក្សាការងារ និងសម្តែងការគួរសម<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតសិង្ហបុរី ឯកអគ្គរដ្ឋទូតឡាវ គណៈប្រតិភូជប៉ុន គណៈប្រតិភូសាធារណរដ្ឋសង្គមនិយមវៀតណាម អគ្គនាយករង ក្រុមហ៊ុន Yanchang Petroleum ប្រធានផ្នែកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិរបស់ក្រុមហ៊ុនVishu ជប៉ុន និងនាយកប្រតិបត្តិក្រុមហ៊ុន Hyundai Corporation Holdings ចូលជួបពិភាក្សាការងារ សម្តែងការគួរសម និងសវនាការ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទៅទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋបារាំង សាធារណរដ្ឋប្រជាមានិតចិន និងនៅព្រះរាជាណាចក្រថៃឡង់ដ៍ ចូលរួមមហាសន្និបាតលើកទី២៣ នៃសភានិយាយភាសាបារាំង (APF)នៅប្រទេសលុចហ្សំបួរ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយ (AIPA) របស់អន្តរសភាអាស៊ានលើកទី៩ នៅប្រទេសឥណ្ឌូនេស៊ី ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មាធិការស្វែងរកការពិត ដើម្បីប្រយុទ្ធប្រឆាំងគ្រឿងញៀននៃអន្តរសភាអាស៊ាន លើកទី១៣ នៅសាធារណរដ្ឋហ្វីលីពីន ។ | នយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- រៀបចំបែបបទជូនគណៈប្រតិភូ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងទស្សនកិច្ចសិក្សានៅក្រៅប្រទេសសរុបចំនួន៣២នាក់<br>- រៀបចំកន្ត្រកផ្កាចូលរួមក្នុងពិធីផ្សេងៗចំនួន០៥លើក<br>- ធ្វើពិព័រណ៍រូបភាពនៅព្រឹទ្ធសភាចំនួន០៤លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ អន្តរជាតិ មកបំពេញទស្សនចំនួន ២៩លើក<br>- រៀបចំសម្អាត តុបតែងសាល បម្រើ និងផ្តល់សេវាភេសជ្ជៈក្នុងពិធីផ្សេងៗចំនួន០២លើក ស្មើនឹង ២៥នាក់<br>- ថតចម្លងឯកសារចំនួន៩៣ច្បាប់ អស់ក្រដាសចំនួន២,៣២៧សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុងរាជធានីទាំង៨ភូមិភាគចំនួន៧០នាក់ ស្មើនឹង២៩លើក<br>- ធ្វើកំណត់បង្ហាញ លិខិតអញ្ជើញ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន១១លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៨នាក់ ស្មើនឹង១៥ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន |

| | |
|---|---|
| | ព្រឹទ្ធសភាចំនួន១៥លើក<br>- ការពារសន្តិសុខ សុវត្ថិភាព និងរៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៧៩នាក់ ស្មើនឹង០៤លើក<br>- អគ្គលេខាធិការព្រឹទ្ធសភា បានចូលរួមមហាសន្និបាតសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) នៅប្រទេសលុចហ្សំបួរ។ |

## ៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៧៨ច្បាប់។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៥៤ច្បាប់<br>- ប្រជុំគណៈកម្មការគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០១៦<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំអន្តរគណៈកម្មការចំពោះកិច្ច ដើម្បីពិនិត្យសេចក្តីព្រាងសេចក្តីកែសម្រួល សេចក្តីព្រាងសេចក្តីសម្រេចរួមស្តីពី ការធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- រៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ |

| | |
|---|---|
| | ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និង ក្រៅប្រទេស សរុបចំនួន០៥វគ្គ មានសិក្ខាកាម ចូលរួមចំនួន៦១នាក់ សិក្ខាសាលាចំនួន០២លើក មានសិក្ខាកាមចូលរួមចំនួន១៧០នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសសម្រាប់ មន្ត្រីសភា និងបន្តអនុវត្តកម្មវិធីកម្មសិក្សាជាមួយ និស្សិតកូរ៉េ ។<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ :<br>- ប្រជុំសិក្សាអំពីអង្គភាពថវិកាតាមកម្មវិធី និង សមិទ្ធកម្មកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ<br>- ប្រជុំការពារគម្រោងថវិកាឆ្នាំ២០១៨ របស់ព្រឹទ្ធសភា កម្រិតជំនាញ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- រៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (២០១៨-២០២០) និងគម្រោងថវិកាប្រចាំឆ្នាំ២០១៨ របស់ ព្រឹទ្ធសភា<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់ បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិ ប្រចាំខែកក្កដាឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលរថយន្ត និងសម្ភារៈឧបករណ៍បច្ចេកទេស ផ្សេងៗ ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធ កែលម្អសោភ័ណ្ឌភាពក្នុងបរិវេណព្រឹទ្ធសភាចំនួន |

| | |
|---|---|
| | ១២២លើក<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន១៦សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៤៧សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល ផ្ដល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន២៧លើក មានអ្នកចូលរួមចំនួន១,៨១៧នាក់<br>- ផ្ដល់សេវាថវិកាសម្រាប់មន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន១០៣លើក<br>- ថតចម្លងឯកសារបានចំនួន៤,៩៥៤ច្បាប់ និងចងក្រងសៀវភៅចំនួន៥៣ក្បាល អស់ក្រដាសចំនួន៤៥,២៥២សន្លឹក<br>- ផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគចំនួន១៩៦នាក់ ស្មើនឹង៥៥លើក ។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:<br>- រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជា-មានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤ព្រឹទ្ធសភា<br>- សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី និងដំណើរការជួសជុលអគារមូលនិធិអភិវឌ្ឍន៍ |

| | |
|---|---|
| | - សាងសង់បន្ទប់ការិយាល័យបន្ថែម និងបន្ទប់ទឹក នៅអគារមូលនិធិអភិវឌ្ឍន៍ ព្រមទាំងសាងសង់រោងចំណតរថយន្តនៅខាងមុខអគារខុទ្ទកាល័យ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ជួសជុល កែលម្អ ខាត់ លាប បាញ់ថ្នាំ និងប្តូរក្រណាត់កៅអីឈើទឹកមាសដាក់នៅសាលប្រជុំអគារក្រហម<br>- រៀបចំសុំគោលការណ៍ ដើម្បីត្រៀមរៀបចំជួសជុលអគារសាលប្រជុំពេញអង្គចាស់<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឲ្យមានសោភ័ណ្ឌភាពល្អ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច ប្តូរសោតុ ដៃទ្វារ សរុបចំនួន៧១គ្រឿង<br>- បិទលេខកូដទូដាក់សៀវភៅចំនួន០១គ្រឿង<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួនគ្រឿង២៨ ។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៧៨ ចំណងជើង ។<br>+ការងារផ្សេងៗ:<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ សៀវភៅជំនាញផ្សេងៗ និងចុះបញ្ជីឯកសារបោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ជួសជុល |

| | |
|---|---|
| | និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន២១៤ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន៥,២១៩ ក្បាល ។ |

**II.ទិសដៅការងារខែសីហា ឆ្នាំ២០១៧**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៣

-ត្រៀមបោះពុម្ពអត្ថបទច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងថ្មី

-ត្រៀមបោះពុម្ពសៀវភៅច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រធានព្រឹទ្ធសភា ជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមទទួលដំណើរទស្សនកិច្ចគណៈប្រតិភូអគ្គលេខាធិការព្រឹទ្ធសភាប៉ាគីស្ថាន(ខែធ្នូ ឆ្នាំ២០១៧) និងគណៈប្រតិភូសភាក្រុមប្រឹក្សានយោបាយប្រជាជនចិន (ខែសីហា និងខែកញ្ញា ឆ្នាំ២០១៧ )

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-ចូលរួមវេទិកាសភាតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី៣ នៅប្រទេសជប៉ុន

-ទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន និងចូលរួមប្រជុំ(IPU) នៅប្រទេសរុស្ស៊ី (ខែតុលា ឆ្នាំ២០១៧)

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO, JICA និង KOICA

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-បន្តបណ្តុះបណ្តាលការងារ (PBO) អ្នកស្រាវជ្រាវទូទៅ អ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ និងការបោះពុម្ពសៀវភៅ Atlas

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការអនុវត្ត( MOU) សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់រួមមាន អគារសាលប្រជុំពេញអង្គ អគារមូលនិធិខ្មែរអភិវឌ្ឍន៍ អគារការិយាល័យសមាជិកព្រឹទ្ធសភា និងក្នុងអគារថ្នាក់ដឹកនាំព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងស្លាកសញ្ញាបង្ហាញផ្លូវ (ផ្នែកខាងជើង)

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុង និងការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអំពីលក្ខន្តិកៈសមាគមសង្គហៈមន្ត្រីរាជការក្រុមនីតិបញ្ញត្តិ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បច្ចុប្បន្នភាពឯកសារគោលការណ៍សិក្សាស្តីពី ទស្សនៈវិស័យនៃដំណើរការទៅមុខរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៨-២០២៤)

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ

ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រភពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាតាមកម្មវិធីជាក់ស្តែងក្នុងត្រីមាសទី៣ ឆ្នាំ២០១៧

-រៀបចំគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៨ និងការត្រៀមការពារគម្រោងថវិកាឆ្នាំ២០១៨ របស់ព្រឹទ្ធសភា កម្រិតនយោបាយ

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៨ និងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ

-រៀបចំធ្វើរបាយការណ៍ចំណូល និងចំណាយថវិកាឆមាសទី១ ឆ្នាំ២០១៧

- រៀបចំរបាយការណ៍សកម្មភាពឆមាសទី១ និងទិសដៅឆមាសទី២ ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន ០១លើក ព្រមទាំងផ្តល់សេវាលើមុខងារផ្សេងៗទៀត ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានដោយរលូន ។ ការអភិវឌ្ឍស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ ចំពោះការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ មានភាពមមាញឹកត្រូវបានពង្រឹងពង្រីក និងលើកកម្ពស់តាមរយៈការចូលរួមប្រជុំមហាសន្និបាត និងទស្សនកិច្ចសិក្សានៅប្រទេសបារាំង ថៃឡង់ដ៍ ចិន ហ្វីលីពីន ឥណ្ឌូនេស៊ី និងប្រទេសលុចហ្សំបួរ ។៚

ភ្នំពេញ, ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ